# [សំខាន់] ប្រការប្រុងប្រយ័ត្ននៅថ្ងៃប្រលង

**កម្រិតដំបូង**

## 1. អំពីការផ្លាស់ប្តូរសម្លៀកបំពាក់

សូមកុំផ្លាស់ប្តូរសម្លៀកបំពាក់ រហូតដល់អនុរក្សប្រលងណែនាំ។
សូមពាក់សម្លៀកបំពាក់ការងារ អាវនិងស្លៀកខោ នៅទីតាំងដែលកំណត់ដោយOTAFF
ហើយសូមពាក់អាវយឺតពីក្នុងសម្លៀកបំពាក់ការងារ។(មួកគឺជាលំហាត់នៃការប្រលងនឹងអោយពាក់នៅពេលក្រោយ។)

## 2. អំពីការគ្រប់គ្រងរបស់មានតម្លៃ

**ដោះគ្រឿងអលង្ការចេញ**

សូមដោះចេញនូវគ្រឿងអលង្ការទាំងអស់គ្រប់ប្រភេទ

ហើយដាក់ក្នុងកាបូប។



**ការគ្រប់គ្រងរបស់មានតម្លៃ**

របស់មានតម្លៃគឺគ្រប់គ្រងដោយខ្លួនឯង។

សូមធ្វើយ៉ាងណាកុំឲ្យមានរបស់ភ្លេច ឬរបស់ជ្រុះជាដើម។



**កុំឲ្យមានអ្វីក្នុងហោប៉ៅ**

សូមកុំដាក់អ្វីចូលក្នុងហោប៉ៅឲ្យសោះ។



## 3. អំពីប្រការប្រុងប្រយ័ត្នក្នុងអគារមណ្ឌល

**សុជីវធម៌**

មិនត្រូវខ្សឹបខ្សៀវគ្នានៅអគារមណ្ឌល ឬមណ្ឌលប្រលងទេ។

មិនត្រូវធ្វើសកម្មភាពណាដែលបង្កការរំខានដល់អ្នកជុំវិញខ្លួនទេ។

**ត្រូវបិទឧបករណ៍អេឡិចត្រូនិក**

សូមបិទឧបករណ៍អេឡិចត្រូនិក ដូចជាស្មាតហ្វូនជាដើម

ហើយដាក់ក្នុងកាបូប។




**ហាមថត**

ការថតរូប ឬថតវីដេអូនៅអគារមណ្ឌល ឬមណ្ឌលប្រលងគឺហាមឃាត់។

* អ្នកដឹកនាំទៅ ក៏ហាមឃាត់ដែរ។



**ការប្រើបន្ទប់ទឹក**

ការផ្លាស់ប្តូរសម្លៀកបំពាក់ ហូបឬផឹក នៅក្នុងបន្ទប់ទឹកគឺហាមឃាត់។



# [សំខាន់] ប្រការប្រុងប្រយ័ត្ននៅថ្ងៃប្រលង

## 4. អំពីការចុះឈ្មោះ

**ការបញ្ជាក់អត្តសញ្ញាណសាមីខ្លួន**

យើងនឹងឲ្យអ្នកដោះម៉ាស់ និងវ៉ែនតាចេញ ដើម្បីពិនិត្យបញ្ជាក់ មុខរបស់អ្នក។



**ការសរសេរលើដៃ**

យើងនឹងពិនិត្យបញ្ជាក់ថា អ្នកបានសរសេរនៅលើបាតដៃ និងខ្នងដៃឬទេ។



## 5. អំពីរបៀបសរសេរឈ្មោះជាដើម នៅលើសំណួរប្រលង

* សំណួរប្រលងដែលត្រូវបានចែកនៅថ្ងៃនោះ សរសេរដោយភាសាជប៉ុនទាំងអស់។




កាលបរិច្ឆេទប្រលង សូមសរសេរដោយមើលលើក្តារខៀននៅក្នុងមណ្ឌលប្រលង។

សូមសរសេរអត្តលេខប្រលង និងឈ្មោះដោយមើលប័ណ្ណប្រលង។



# [សំខាន់] ប្រការប្រុងប្រយ័ត្ននៅថ្ងៃប្រលង

## 6. អំពីរបៀបឆ្លើយសំណួរសរសេរ

(1) នៅពេលក្រដាសសំណួរត្រូវបានចែក សូមកុំបើករហូតដល់មានការណែនាំ។

(2) នៅពេលមានការណែនាំ សូមបើកក្រដាសសំណួរ ហើយបត់វាជាពីរ។

(3) នៅពេលធ្វើសំណួរនៅផ្នែកខាងក្រោយ សូមបត់ក្រដាសសំណួរប្រលងជាពីរ។




(4) អនុរក្សប្រលង នឹងអានសំណួរប្រលងចំនួន2ដង។

(5) អ្នកក៏អាចសរសេរចម្លើយបានដែរ នៅពេលអនុរក្សកំពុងអានសំណួរ។

(6) នៅពេលសរសេរចម្លើយរួចហើយ សូមដាក់ខ្មៅដៃចុះ។

* បើអ្នកដាក់ខ្មៅដៃចុះ វានឹងក្លាយជាសញ្ញាបញ្ជាក់ថា អ្នកបានសរសេរចម្លើយរួច។



### របៀបសរសេរនៅក្រឡានចម្លើយ

★学科試験（がっかしけん）

ប្រសិនបើគិតថាត្រូវ សូមគូស “ ✓ ” នៅក្រឡាន "〇"

ប្រសិនបើគិតថាខុស សូមគូស “ ✓ ” នៅក្រឡាន "×"




★実技判断等試験（じつぎはんだんとうしけん）・製作等作業試験（せいさくとうさぎょうしけん） 加熱（かねつ）

សូមជ្រើសរើសចម្លើយដែលគិតថាត្រឹមត្រូវហើយសូមសរសេរដោយអក្សរអង់គ្លេស។




(7) នៅពេលដល់ពេលវេលាកំណត់មួយ គេនឹងសួរថា (“kakemashitaka ?” “សរសេររួចហើយឬនៅ?”)។

ចំពោះអ្នកដែលបានសរសេររួចហើយ សូមលើកដៃដោយស្ងៀមស្ងាត់។

(8) នៅពេលលើកដៃទាំងអស់គ្នា គេនឹងបន្តទៅសំណួរបន្ទាប់។

* បើផុត2នាទី គេនឹងបន្តទៅសំណួរបន្ទាប់ ទោះជាអ្នកមិនទាន់បញ្ចប់ក៏ដោយ។



(9) នៅពេលបញ្ចប់សំណួរទាំងអស់ នឹងមានរយៈពេល (ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ “ minaoshi ”) ចំនួន3នាទី។

សូម (ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ “ minaoshi ”) រហូតដល់ម៉ោងបញ្ចប់។

* (ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ “ minaoshi ”) គឺជាការពិនិត្យថាតើមានកំហុសណាមួយឬទេ។

(10) នៅពេលដល់ម៉ោង សូមដាក់ក្រដាសផ្នែកមុខបែរទៅលើ។ អនុរក្សប្រលងនឹងប្រមូលយក។

# [សំខាន់] ប្រការប្រុងប្រយ័ត្ននៅថ្ងៃប្រលង

**កម្រិតដំបូង**

## 7. ស្ដីអំពីរបៀបបន្តនៃ製作等作業試験(せいさくとうさぎょうしけん)

(1) អនុរក្សប្រលងនឹងអានសំណួរហើយនិយាយថា (សូមចាប់ផ្ដើម“Hajimetekudasai”)។

(2) ដោយសារតែបន្តការងារពេលជាមួយគ្នាទាំងអស់គ្នា ដូច្នេះសូមធ្វើការងារត្រឹមកន្លែងដែលបានអានដល់។

(មិនអាចធ្វើទៅមុនដោយចិត្តឯងបានទេ។)

* អ្នកដែលប្រលង 加熱(かねつ)、 នៅពាក់កណ្ដាលទីមានការប្រលងសំណួរសរសេរ។（作業手順書(さぎょうてじゅんしょ)「3　かねつちょうり」）

## 8. អំពីសកម្មភាពមិនត្រឹមត្រូវ

**នៅពេលគេរកឃើញថា អ្នកបានធ្វើសកម្មភាពដូចខាងក្រោម នោះអ្នកនឹងត្រូវអស់សិទ្ធិប្រលង (នឹងត្រូវធ្លាក់)។ សូមប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់។**

### លួចចម្លង



មិនត្រូវមើលចម្លើយរបស់បេក្ខជនប្រលងផ្សេងទេ។

### ប្រាប់គេ




មិនត្រូវប្រាប់ចម្លើយទៅអ្នកជុំវិញ ឬជួយគ្នាទេ។

### និយាយ



មិនត្រូវនិយាយម្នាក់ឯង ឬនិយាយជាមួយអ្នកនៅជុំវិញទេ។

### ដើរចេញពីកន្លែងអង្គុយដោយគ្មានការអនុញ្ញាត



នៅពេលដើរចេញពីកៅអីអង្គុយ សូមលើកដៃ ហើយប្រាប់ដល់អនុរក្សប្រលង។

### សរសេរចម្លង




មិនត្រូវសរសេរចម្លងសំណួរប្រលង ឬចម្លើយជាដើម ទៅលើប័ណ្ណប្រលង ឬលើដៃជាដើមទេ។

### មើលការកត់ត្រា



មិនត្រូវមើលឯកសាររៀន ឬការកត់ត្រាជាដើម នៅពេលកំពុងប្រលងទេ។

**ទោះជានៅមុនពេលចាប់ផ្ដើមការប្រលងក៏ដោយ ក្នុងករណីមានសរសេរអក្សរជាដើមនៅលើប័ណ្ណប្រលងឬនៅលើដៃ គេនឹងចាត់ទុកថាជាសកម្មភាពមិនត្រឹមត្រូវ។ សូមប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់។**

## 9. ប្រការប្រុងប្រយ័ត្នពេលកំពុងប្រលង

### នៅពេលមានអាការៈមិនស្រួល



នៅពេលមិនស្រួលខ្លួន សូមលើកដៃហើយប្រាប់ដល់អនុរក្សប្រលង។

### ពេលកើតមានគ្រោះមហន្តរាយ



សូមធ្វើការជម្លៀសខ្លួនទៅតាមការណែនាំរបស់អនុរក្សប្រលង។